ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ចការងារ
និងអតីតយុទ្ធជន
លេខ ០៤ សករ

ភ្នំពេញ.ថ្ងៃទី ០3 ខែ មីនា ឆ្នាំ១៩៩៧

## សេចក្តីជូនដំណឹង

ក្រសួងសង្គមកិច្ចការងារ និងអតីតយុទ្ធជន សូមជូនដំណឹងដល់កម្មករនិយោជិត នៅតាម រោងចក្រកាត់ដេរទូទាំងរាជធានីភ្នំពេញថា នៅថ្ងៃទី១៧ ខែមករា ឆ្នាំ១៩៩៧ ក្រសួងសង្គមកិច្ចការងារ និងអតីតយុទ្ធជន បានបន្តធ្វើការពិភាក្សាជាមួយសមាគមអ្នកផលិតសំលៀកបំពាក់ ដើម្បីកំណត់អំពីលក្ខខណ្ឌការងារ របស់កម្មករ និយោជិត នៃរោងចក្រកាត់ដេរនៅរាជធានីភ្នំពេញ ។

ឆ្លងតាមការប្រជុំ សមាគមបានយល់ព្រមដូចតទៅនេះ :

១-ប្រាក់ឈ្នួលសុទ្ធសាធអប្បបរមាសំរាប់កូនជាងដែលមកសុំរៀនកាត់ដេរត្រូវបានកំណត់៣០ដុល្លាក្នុងមួយខែ ។ការហ្វឹកហ្វឺនកូនជាងនេះមានថិរវេលាអតិបរមា២ខែ ។ ចប់រយៈពេលហ្វឹកហ្វឺនកូនជាងត្រូវបានធ្វើតេស្តវាស់កំរិតជំនាញ ។ បើជាប់ជំនាញហើយកូនជាងត្រូវបញ្ជូនអោយសាកល្បងថែមទៀត ។

២-មុនក្លាយទៅជាជាងកាត់ដេរ កូនជាងដែលបានបញ្ចប់ការហ្វឹកហ្វឺនប្រកបដោយជោគជ័យ ត្រូវឆ្លងកាត់ការសាកល្បងដែលមានថិរវេលាអតិបរមា៣ខែ។ក្នុងថិរវេលាសាកល្បង អ្នកសាកល្បងបានទទួលប្រាក់ឈ្នួលសុទ្ធសាធអប្បបរមា ៤០ដុល្លាក្នុងមួយខែ។

៣-កម្មករនិយោជិតដែលបានឆ្លងកាត់ការសាកល្បងប្រកបដោយជោគជ័យ ក្លាយទៅជាជាងដេរដែលបានទទួលប្រាក់ឈ្នួលសុទ្ធសាធអប្បបរមា៤០ដុល្លាក្នុងមួយខែ ។

៤-កម្មករនិយោជិតចាស់ដែលមានសៀវភៅការងារហើយត្រូវឆ្លងកាត់ថិរវេលាសាកល្បង៣ខែទៀត បើសិនជាគេផ្លាស់មកធ្វើការនៅក្នុងក្រុមហ៊ុនថ្មី។ក្នុងថិរវេលាសាកល្បងនេះកម្មករនិយោជិត បានទទួលប្រាក់ឈ្នួលសុទ្ធសាធអប្បបរមា៤០ដុល្លាក្នុងមួយខែ ។

៥-មុននឹងបញ្ឈប់កូនជាងអ្នកសាកល្បងឬកម្មករនិយោជិតពីការងារ និយោជកត្រូវជូនដំណឹងមុនតាមថិរវេលាដូចខាងក្រោមនេះលើកលែងតែករណីមានកំហុសធ្ងន់ :

-មួយថ្ងៃមុនចំពោះកូនជាង

-មួយសប្តាហ៍មុនចំពោះអ្នកសាកល្បង

-ថិរវេលាដូចមានចែងក្នុងច្បាប់ការងារ ចំពោះកម្មករ និយោជិត ។

៦-ថិរវេលាធ្វើការអតិបរមាគឺ៤៨ម៉ោងក្នុងមួយសប្តាហ៍។ថិរវេលានេះអាចកើនឡើងនេះអាស្រ័យលើ

ការព្រមព្រៀងគ្នារវាងនិយោជក និងកម្មករ និយោជិត ។

៧.និយោជកអាចសុំឲ្យមកអោយកម្មករ និយោជិតធ្វើការបន្ថែមម៉ោងប្តូរម្លាល់ក្នុងល័ក្ខខណ្ឌដូចខាងក្រោមនេះ:.

.ការធ្វើការបន្ថែមម៉ោងត្រូវមានការស្ម័គ្រចិត្តពីកម្មករនិយោជិត

.អត្រាប្រាក់បន្ថែមម៉ោងក្នុងថ្ងៃធ្វើការធម្មតាស្មើនឹង១.៥ដងនៃប្រាក់ឈ្នួលថ្ងៃធម្មតា ឬបន្ថែម៥០% លើប្រាក់ឈ្នួលធម្មតា

.ប្រាក់ធ្វើការថ្ងៃឈប់សំរាកប្រចាំសប្តាហ៍ និងថ្ងៃបុណ្យត្រូវផ្តល់ស្មើនឹង២ដងនៃប្រាក់ឈ្នួលថ្ងៃធម្មតា ឬបន្ថែម១០០%លើប្រាក់ឈ្នួលធម្មតា។

៨.និយោជកឯកភាពផ្តល់ការចំណាយទាំងអស់ផ្នែកពេទ្យដល់កម្មករ និយោជិតដែលមានគ្រោះថ្នាក់ការងារ។និយោជកផ្តល់ការព្យាបាលនិងប្រាក់ថ្លៃថ្នាំពេទ្យរបស់កម្មករ និយោជិតដែលមានជម្ងឺតាមលទ្ធភាពរបស់ខ្លួន។និយោជកត្រូវបង្កើតគិលានដ្ឋានដើម្បីពិនិត្យព្យាបាលជម្ងឺស្រាលៗរបស់កម្មករ និយោជិតសមស្របតាមការកំណត់របស់ច្បាប់ការងារ។

៩.និយោជកអនុញ្ញាតអោយកម្មករ និយោជិតជាស្ត្រីភេទបានឈប់សំរាកមាតុភាពចំនួន៩០ថ្ងៃ ដោយទទួលបានប្រាក់ឈ្នួលពាក់កណ្តាល ។

១០.និយោជក នឹងបណ្តេញពីការងារនូវកម្មករនិយោជិតណាដែលមានកំហុសធ្ងន់ដូចមានចែងក្នុងច្បាប់ការងារ។ករណីមានកំហុសធ្ងន់ធ្ងរខ្លាំង និយោជកនឹងបញ្ជូនសាម៉ីខ្លួន និងករណីទៅស្ថាប័នមានសមត្ថកិច្ច ដើម្បីដោះស្រាយតាមផ្លូវច្បាប់។ក្នុងករណីទាំងពីរនេះកម្មករ និយោជិតដែលមានកំហុសនៅទទួលបានប្រាក់ឈ្នួលចំពោះការងារដែលខ្លួនបានធ្វើកន្លងមកហើយមិនទាន់បានបើក ។

១១.ក្នុងការបញ្ឈប់កម្មករ និយោជិតក្រៅពីកំហុសធ្ងន់ និយោជកត្រូវផ្តល់ប្រាក់បំណាច់បណ្តេញមិនតិចជាងការកំណត់របស់ច្បាប់ការងារឡើយ ។

១២.ប្រតិភូបុគ្គលិកត្រូវបានជ្រើសរើសក្នុងចំណោមបេក្ខជនដែលឧទ្ទេសនាមដោយអង្គការសហជីព។ក្នុងសភាពការណ៍បច្ចុប្បន្នដែលនៅមិនទាន់មានអង្គការសហជីពបេក្ខជនប្រតិភូបុគ្គលិកត្រូវជ្រើសរើសដោយកម្មករ និយោជិតផ្ទាល់ ។

១៣.និយោជកឯកភាពផ្តល់ដល់កម្មករ និយោជិតនូវប្រាក់ឈ្នួលបន្ទាប់បន្សំដូចខាងក្រោមនេះ :.

ក.ប្រាក់រង្វាន់លើកទឹកចិត្តចំពោះការងារទៀងទាត់ ។និយោជកនឹងពិភាក្សាជាមួយកម្មករ និយោជិតផ្ទាល់ដើម្បីកំណត់បរិមាណប្រាក់រង្វាន់នេះ ។

ខ.មធ្យោបាយដឹកជញ្ជូននៅពេលដែលក្រុមហ៊ុនមានលទ្ធភាព ។ចំពោះមុខនិយោជកឯកភាពផ្តល់ជាប្រាក់ជំនួសសិន ។និយោជកនឹងពិភាក្សាជាមួយកម្មករ និយោជិតអំពីចំនួនប្រាក់ដែលត្រូវផ្តល់អោយកម្មករ និយោជិត ។

គ.ប្រាក់រង្វាន់ប្រចាំឆ្នាំ ករណីដែលរោងចក្រចំណេញ និងអនុវត្តចំពោះកម្មករ និយោជិតដែលធ្វើការបានមួយឆ្នាំពេញ ។

ឃ.សំលៀកបំពាក់ពលកម្ម២សំរាប់ម្នាក់ក្នុងមួយឆ្នាំដោយឥតគិតថ្លៃ ចំពោះកម្មករ និយោជិតណាដែលធ្វើការចាប់ពី៦ខែឡើងទៅដោយគិតទាំងរយៈពេលសាកល្បងផង ។

ង.ក្រុមហ៊ុនឯកភាពផ្តល់នូវបាយមួយពេលដោយឥតគិតថ្លៃ ចំពោះកម្មករ និយោជិតណាដែលធ្វើការបន្ថែមម៉ោង ។

១៤.ក្រុមហ៊ុនសន្យាថា នឹងអនុវត្តតាមបទបញ្ញត្តិនៃច្បាប់ការងារ ឬសេចក្តីសំរេចណារបស់ រដ្ឋាភិបាលដែលផ្តល់លក្ខខណ្ឌប្រសើរជាងសំរាប់កម្មករ និយោជិត ។

១៥.ក្រុមហ៊ុនសន្យាថានឹងដោះស្រាយជាមួយកម្មករនិយោជិតនូវវិវាទដែលកើតមានឡើងដោយសន្តិវិធី ។ បើដោះស្រាយមិនបានសំរេចក្រុមហ៊ុននឹងស្នើអោយក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជនដោះស្រាយបន្ត ។

ចំពោះបញ្ហាដែលនៅសេសសល់ក្រសួងនឹងបន្តពិភាក្សាជាមួយសមាគមថែមទៀត ហើយក្រសួងនឹងជូនដំណឹងជាបន្តបន្ទាប់ ។

អាស្រ័យហេតុនេះ ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន សូមអោយបងប្អូនកម្មករ កម្មការិនី និងនិយោជិតទាំងអស់មេត្តាជ្រាប ។

រដ្ឋលេខាធិការក្រសួងសង្គមកិច្ច ការងារនិងអតីតយុទ្ធជន

ស៊ុយ សែម

ចម្លងជូន

-ព្រះរាជលេខាធិការដ្ឋានព្រះមហាក្សត្រ
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចក្រុមព្រះ នាយករដ្ឋមន្ត្រីទី១
-ខុទ្ទកាល័យសម្តេច នាយករដ្ឋមន្ត្រីទី២
-ក្រសួងព័ត៌មាន
-អគ្គនាយកវិទ្យុ និងទូរទស្សន៍កម្ពុជា
-គ្រប់បណ្តាញទូរទស្សន៍ និងវិទ្យុ
"ដើម្បីមេត្តាជួយផ្សព្វផ្សាយឱ្យបានច្រើនផង"
-សមាគមនិយោជករោងចក្រផលិតសំលៀកបំពាក់
"ដើម្បីផ្សព្វផ្សាយដល់គ្រប់សមាជិក"
-ប្រតិភូបុគ្គលិកគ្រប់ក្រុមហ៊ុនពាក់ព័ន្ធ
-ឯកសារ -កាលប្បវត្តិ